CITY OF LONGBEACH PRESS RELEASE

**សេចក្តីប្រកាសព័ត៌មាន**

ថ្ងៃទី 1 ខែមិថុនា ឆ្នាំ 2021
ទំនាក់ទំនង ៖ មជ្ឈមណ្ឌលព័ត៌មានរួម នៃសាលាក្រុងឡុងប៊ិច, 562.570.NEWS, jic@longbeach.gov

សម្រាប់ការផ្សព្វផ្សាយភ្លាមៗ

# ប្រជាពលរដ្ឋ ត្រូវបានជំរុញឱ្យចាក់វ៉ាក់សាំង ដើម្បីអាចចូលរួម កម្មវិធីលើកទឹកចិត្តរបស់មូលដ្ឋាន និងរដ្ឋ ដោយសាររដ្ឋត្រៀមលក្ខណៈ បើកដំណើរការសេដ្ឋកិច្ច ពេញលេញឡើងវិញ

*រដ្ឋផ្តល់ប័ណ្ណអំណោយ និងរង្វាន់សាច់ប្រាក់ ។ សាលាក្រុងបន្តរៀបចំកម្មវិធីចាប់ឆ្នោតផ្សងសំណាង ។*

ឡុងប៊ិច, CA - សាលាក្រុងឡុងប៊ិច កំពុងលើកទឹកចិត្ត សមាជិកសហគមន៍ ឱ្យចាក់វ៉ាក់សាំង COVID-19 ដើម្បីអាចទទួលបាន ប័ណ្ណអំណោយ និងរង្វាន់សាច់ប្រាក់ ពីរដ្ឋកាលីហ្វ័រញ៉ា ហើយបានចុះឈ្មោះ ចាប់ឆ្នោតផ្សងសំណាងប្រចាំថ្ងៃ ដែលរៀបចំដោយនាយកដ្ឋានសុខាភិបាល និងសេវាមនុស្ស នៃសាលាក្រុងឡុងប៊ិច (នាយកដ្ឋានសុខាភិបាល) ។ កម្មវិធីលើកទឹកចិត្តនេះ មានគោលដៅជំរុញបុគ្គលម្នាក់ៗ ឱ្យចាក់វ៉ាក់សាំង ប្រឆាំង COVID-19 ដោយកាលីហ្វ័រញ៉ា បោះជំហ៊ាន ទៅបើកដំណើរការសេដ្ឋកិច្ច ឡើងវិញ ឱ្យបានពេញលេញ នៅថ្ងៃទី 15 ខែមិថុនា ។

ចៅហ្វាយក្រុង រ៉ូប៊ើត ហ្គាសៀ (Mayor Robert Garcia) បានលើកឡើងថា «យើងខ្ញុំបន្តឃើញ ជោគជ័យអស្ចារ្យ ក្នុងកម្មវិធីលើកទឹកចិត្ត នៅមូលដ្ឋានរបស់យើង ។» «យើងខ្ញុំសូមអរគុណ ដល់ដៃគូសហគមន៍ របស់យើង ដែលបានជួយ ក្នុងកិច្ចខិតខំប្រឹងប្រែងនេះ ហើយសង្ឃឹមថា នេះ រួមជាមួយ កម្មវិធីលើកទឹកចិត្ត នៅទូទាំងរដ្ឋ នឹងលើកទឹកចិត្តប្រជាពលរដ្ឋ ឱ្យមកចាក់វ៉ាក់សាំង បានកាន់តែច្រើនឡើង នៅថ្ងៃ និងសប្តាហ៍ ខាងមុខនេះ ។»

**កម្មវិធីលើកទឹកចិត្ត ចាក់វ៉ាក់សាំងឈ្នះរង្វាន់របស់រដ្ឋ**

រដ្ឋកាលីហ្វ័រញ៉ា បានដាក់ឱ្យដំណើរការ កម្មវិធីលើកទឹកចិត្ត ដែលមានទឹកប្រាក់ 116.5 លានដុល្លារ សម្រាប់ប្រជាពលរដ្ឋ ដែលបានចាក់វ៉ាក់សាំង ។ កម្មវិធីលើកទឹកចិត្តចាក់វ៉ាក់សាំងនេះ គឺជាកម្មវិធីធំជាងគេ នៅក្នុងប្រទេស ហើយរួមមានរង្វាន់ជាសាច់ប្រាក់ រហូតដល់ 1.5 លានដុល្លារ ។ ប្រជាពលរដ្ឋកាលីហ្វ័រញ៉ាទាំងអស់ ដែលបានចាក់វ៉ាក់សាំង COVID-19 រួច យ៉ាងហោចណាស់ បានមួយដូស រួមទាំងអ្នកដែលកំពុងចាក់វ៉ាក់សាំងនៅឡុងប៊ិច នឹងបានចុះឈ្មោះដោយស្វ័យប្រវត្តិ ។ បុគ្គលម្នាក់ៗ ត្រូវបានលើកទឹកចិត្ត ឱ្យចាក់វ៉ាក់សាំង ឱ្យបានឆាប់ តាមដែលអាចធ្វើទៅបានដើម្បីទទួលបានឱកាសឈ្នះប័ណ្ណរង្វាន់ តម្លៃ 50 ដុល្លារ និងរង្វាន់សាច់ប្រាក់ផ្សេងៗទៀត ។

**កម្មវិធីលើកទឹកចិត្តចាក់វ៉ាក់សាំង នៅឡុងប៊ិច**

សាលាក្រុងឡុងប៊ិច កំពុងបន្តផ្តល់កម្មវិធីលើកទឹកចិត្ត សម្រាប់អ្នកមកចាក់ ដូសដំបូង នៃវ៉ាក់សាំង Pfizer ឬ Moderna COVID-19 ឬ ដូសតែមួយ នៃវ៉ាក់សាំង Johnson & Johnson/Janssen នៅទៅតាំងចាក់វ៉ាក់សាំង ប្រតិបត្តិការ ដោយសាលាក្រុង ។ ពីថ្ងៃទី 1 ដល់ថ្ងៃទី 5 ខែមិថុនា អ្នកដែលមកចាក់វ៉ាក់សាំង នឹងត្រូវបានចុះឈ្មោះដោយស្វ័យប្រវត្តិ ដើម្បីចាប់ឆ្នោតផ្សងសំណាង ឈ្នះរង្វាន់ ជាជម្រើសដូចជា កង់ម៉ាក Sun Bicycles Revolutions 24 beach cruiser, កង់ម៉ាក a Firmstrong Urban Lady Single Speed beach cruiser, ប្រដាប់ចាក់តន្ត្រី Apple Airpods ឬ ការស្នាក់នៅ រយៈពេលមួយយប់ ឬពីរយប់ នៅតាមសណ្ឋាន ក្នុងមូលដ្ឋាន ។ អ្នកដែលត្រូវបានជ្រើសរើស នឹងមានឱកាសជ្រើសយក រង្វាន់ណាមក៏បានដែរ ។ ត្រូវមានការយល់ព្រម ពីឪពុកម្តាយ/អាណាព្យាបាល សម្រាប់អ្នកដែលមានអាយុ ក្រោម 18 ឆ្នាំ។ សណ្ឋាគារចូលរួមកម្មវិធី ក្នុងសប្តាហ៍នេះ រួមមាន ខតយ៉ាត ឡុងប៊ិច ដោនថោន (Courtyard Long Beach Downtown), ហ្គោលឌែន សែល ហូថែល (Golden Sails Hotel), ម៉ារីយ៉ូត ឡុងប៊ិច (Marriott Long Beach) និង វេស្ទីន ឡុងប៊ិច (Westin Long Beach) ។

លើសពីនេះទៅទៀត នៅរៀងរាល់ថ្ងៃពុធ ពេញមួយខែមិថុនា ហាង ហាប៊ិត ប៊ឺហ្គឺ (Habit Burger) នឹងមានវត្តមាន នៅគ្លីនិកចាក់វ៉ាក់សាំង ពេលល្ងាចនៅបរិវេណមហាវិទ្យាល័យ ប៉ាស៊ីហ្វិក ខូស្ត (PCC) នៃទីក្រុងឡុងប៊ិច ដើម្បីផ្តល់អាហារ ឥតគិតថ្លៃ ជូនអ្នកគ្រប់គ្នា ដែលមកចាក់វ៉ាក់សាំងទៀតផង ។

មានមធ្យោបាយជាច្រើន សម្រាប់អ្នកអាចចាក់វ៉ាក់សាំង មកចាក់វ៉ាក់សាំង នៅឡុងប៊ិចបាន ៖

- មជ្ឈមណ្ឌលសន្និសិទ ឡុងប៊ិច ដែលមានអាសយដ្ឋានលេខ 300 មហាវិថី អ៊ី អូស៊ីន (E. Ocean Blvd.) នៅថ្ងៃចន្ទ ថ្ងៃអង្គារ ថ្ងៃពុធ និងថ្ងៃសុក្រ វេលាម៉ោង 11 ថ្ងៃ ដល់ម៉ោង 5 ល្ងាច, នៅថ្ងៃព្រហស្បតិ៍ វេលាម៉ោង 11 ថ្ងៃ ដល់ម៉ោង 6 ល្ងាច និងនៅថ្ងៃសៅរ៍ វេលាម៉ោង 10 ព្រឹក ដល់ម៉ោង 3 រសៀល។
- គ្លីនិកសហគមន៍ ចល័តនៅឧទ្យាន អ៊ែតមៀរ៉ល ឃីត (Admiral Kidd), ម៉ាកខាតធើ (MacArthur) និង ហហ្វថុន (Houghton)
- យានចាក់វ៉ាក់សាំង ចល័ត សម្រាប់អ្នកចេញពីផ្ទះមិនកើត និងប្រជាពលរដ្ឋ នៅក្នុងតំបន់ រងការប៉ះពាល់ខ្លាំង
- គ្លីនិកចាក់វ៉ាក់សាំង ចល័ត នៅសាលារៀន តាមមូលដ្ឋាន រួមមាន វិទ្យាល័យ ខាប្រ៊ីលឡូ (Cabrillo High School) នៅថ្ងៃសៅរ៍ ពីម៉ោង 10 ព្រឹក ដល់ម៉ោង 1 រសៀល, សាលាបឋមសិក្សា ហ្គ្រាន (Grant Elementary) នៅថ្ងៃពុធ និងថ្ងៃសុក្រ ពីម៉ោង 10:30 ព្រឹក ដល់ម៉ោង 12:30 ថ្ងៃត្រង់, និង អនុវិទ្យាល័យ វ៉ាស៊ីងថុន (Washington Middle School) នៅថ្ងៃអង្គារ និងថ្ងៃព្រហស្បតិ៍ ចាប់ពីម៉ោង 2:30 រសៀល ដល់ម៉ោង 4:30 ល្ងាច ។
- ចាក់វ៉ាក់សាំង នៅពេលល្ងាច នៅ PCC ដែលមានអាសយដ្ឋានលេខ 1305 ហាយវេយ៍ អ៊ី ប៉ាស៊ីហ្វិក ខូស្ត (E Pacific Coast Highway) ពីថ្ងៃចន្ទ ដល់ថ្ងៃសុក្រ វេលាម៉ោង 5 ល្ងាច ដល់ម៉ោង 8 យប់។

មិនចាំបាច់មានការណាត់ជួប ទុកជាមុននោះទេ តែប្រជាពលរដ្ឋដែលចាប់អារម្មណ៍ចង់ធ្វើការណាត់ជួប អាចធ្វើទៅបាន ដោយចូលទៅច្រកចាក់វ៉ាក់សាំង របស់រដ្ឋ MyTurn.ca.gov ឬដោយទូរសព្ទទៅលេខទាន់ហេតុការណ៍ 833.422.4255 សម្រាប់ COVID-19 កាលីហ្វ័រញ៉ា បានផងដែរ ។

**កំណត់ត្រាវេជ្ជសាស្ត្រ**

សាលាក្រុងកំពុងលើកទឹកចិត្តឱ្យបុគ្គលម្នាក់ៗ ពិនិត្យឡើងវិញ លើប័ណ្ណចាក់វ៉ាក់សាំងរបស់ខ្លួន ហើយធានាថា ប័ណ្ណនេះត្រូវបានរក្សាទុក ប្រកបដោយសុវត្ថិភាព ដោយសារវាជាភស្តុតាង ផ្លូវការ នៃការចាក់វ៉ាក់សាំង ហើយមិនអាចដូរបាននោះទេ ។ កំណត់ត្រាចាក់វ៉ាក់សាំង ឌីជីថល អាចរក្សាទុកបាន នៅលើទូរ

សព្ទដៃរបស់លោកអ្នក ដោយឥតគិតថ្លៃ តាមរយៈភាពជាដៃគូ ជាមួយនាយកដ្ឋានសុខភាពសាធារណៈ នៃខោនធីឡូស អ៊ែនជឺឡេស និង ហ៊ែលវ៉ាណា (Healthvana) ដែលជាប្រកមានសុវត្ថិភាព និងអាចទុកចិត្តបាន ងាយស្រួលប្រើប្រាស់ ជាមួយទូរសព្ទដៃសម្រាប់អ្នកជំងឺ ក្នុងការគ្រប់គ្រងកំណត់ត្រាសុខភាពរបស់ពួកគេ ។ បុគ្គលដែលមានអ៊ីនធឺណែតប្រើ ហើយបានចាក់វ៉ាក់សាំងរួច ដោយនាយកដ្ឋានសុខាភិបាល អាចទាក់ទង ទៅបណ្តាញព័ត៌មាន COVID-19 របស់សាលាក្រុង ដើម្បីរកជំនួយ ឱ្យអាចទទួលបានកំណត់ត្រាចាក់វ៉ាក់សាំង របស់ខ្លួន តាមរយៈលេខ 562.570.INFO (4636) ពីថ្ងៃចន្ទ ដល់ថ្ងៃសុក្រ វេលាម៉ោង 9 ព្រឹក ដល់ម៉ោង 5 ល្ងាច ។

ចាប់តាំងពីកម្មវិធីលើកទឹកចិត្តចាក់វ៉ាក់សាំងនេះ បានចាប់ផ្តើមដំណើរការ នៅឡុងប៊ិច កាលពីដើមខែនេះមក ការណាត់ចាក់វ៉ាក់សាំង ដូសដំបូង បានកើនឡើងទ្វេដង ។ កម្មវិធីលើកទឹកចិត្ត បានចាប់ដំណើរការ ដោយមានសំបុត្រចូល ជលវប្បដ្ឋាន ប៉ាស៊ីហ្វិក ដែលបានចែកជូនបាន ប្រមាណ 5700 សន្លឹក ហើយ បានបន្តផ្តល់ជូន ប្រដាប់លេងល្បែង Nintendo Switches ម៉ាស៊ីនចាក់ចម្រៀង Apple Airpods និង ឱកាសស្នាក់នៅ ដោយឥតគិតថ្លៃ រយៈពេល ពីរយប់ នៅមូលដ្ឋាន ក្នុងមូលដ្ឋាន ។ សាលាក្រុង នៅបន្តស្វែងរក គ្រឿងលើកទឹកចិត្ត និងយុទ្ធសាស្ត្រផ្សេងៗ ទៀត ដើម្បីលើកទឹកចិត្ត ប្រជាពលរដ្ឋដែលអាចចាក់វ៉ាក់សាំងបានទាំងអស់ ឱ្យការពារខ្លួនពួកគេ និងមនុស្សជាទីស្រឡាញ់ របស់ពួកគេ ពី COVID-19 ។

សម្រាប់ព័ត៌មានចុងក្រោយបំផុត អំពី COVID-19 ដែលមានសេចក្តីលំអិត អំពីសកម្មភាពទាំងអស់របស់សាលាក្រុងឡុងប៊ិច ក្នុងការរក្សាសុវត្ថិភាព របស់ប្រជាពលរដ្ឋរបស់យើង សូមចូលទៅ long-beach.gov/COVID19 ហើយតាម @LongBeachCity នៅលើ Facebook, Twitter និង Instagram ។ ប្រជាពលរដ្ឋក៏អាចចូលទៅ longbeach.gov/COVID19data ដើម្បីទទួលបានព័ត៌មានបច្ចុប្បន្នភាព ពាក់ព័ន្ធនឹងករណីឆ្លង និងវ៉ាក់សាំង បានផងដែរ ។

# # #